ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

## សេចក្តីអំពាវនាវ
## ចំពោះបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នារាត្រីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមធ្វើការអំពាវនាវដល់បងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃសូមគោរពឱ្យបានល្អនូវអនុសាសន៍របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដោយមិនត្រូវវិលត្រឡប់មកស្រុកកំណើតវិញក្នុងដំណាក់កាល ដែលអាជ្ញាធរថៃកំពុងដាក់បម្រាមហាមប្រជាពលរដ្ឋថៃ និងជនបរទេសមិនឱ្យចល័តពីតំបន់មួយទៅតំបន់មួយ និងកំពុងដាក់វិធានការគ្រប់គ្រង និងបង្ការការរីករាលដាលជំងឺកូវីដ-១៩ ដែលកំពុងកើតឡើងនៅបណ្តាខេត្តមួយចំនួននៃប្រទេសថៃនោះឡើយ។

បងប្អូនពលករដែលមានបំណងវិលត្រឡប់មកស្រុកកំណើតវិញក្នុងដំណាក់កាលនេះ គឺមានហានិភ័យខ្ពស់ទាំងផ្នែកសន្តិសុខ និងផ្នែកសុខភាព។ បងប្អូនអាចប្រឈមនឹងការឃាត់ខ្លួន និងរងការពិន័យរបស់អាជ្ញាធរថៃ ក្នុងពេលធ្វើដំណើរដោយខុសនឹងបម្រាមរបស់អាជ្ញាធរថៃ។ ទន្ទឹមនឹងនេះ ដើម្បីការពារសុខភាពរបស់បងប្អូន និងក្រុមគ្រួសាររបស់បងប្អូន ក៏ដូចជាសុខភាពសាធារណៈ បងប្អូននឹងត្រូវក្រុមការងារចត្តាឡីស័កកម្ពុជានៅតាមច្រកព្រំដែនកម្ពុជា-ថៃ យកសំណាកទៅពិនិត្យជំងឺកូវីដ-១៩ និងដាក់ឱ្យធ្វើចត្តាឡីស័កនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ ចំនួន ១៤ថ្ងៃ បើទោះបីជាបងប្អូនឆ្លងចូលមកប្រទេសកម្ពុជាតាមច្រកណាមួយក៏ដោយ។

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានធ្វើការជាប្រចាំជាមួយភាគីថៃ។ ចំពោះមុខនេះ អាជ្ញាធរថៃមិនចាប់ឃាត់ខ្លួន ឬពិន័យពលករបរទេស និងនិយោជកណាមួយឡើយ ប្រសិនជាពលករបរទេស និងនិយោជកនោះសហការអនុវត្តតាមបទបញ្ជា និងការណែនាំរបស់អាជ្ញាធរថៃ។ ក្នុងពេលដ៏ខ្លីខាងមុខនេះ ក្រសួងមហាផ្ទៃថៃ និងក្រសួងការងារថៃ នឹងរួមគ្នាស្រង់ឈ្មោះពលករបរទេស និងចេញបណ្ណពណ៌ស៊ីជម្ពូដល់ពលករបរទេស ក្នុងនោះក៏មានបងប្អូនពលករកម្ពុជាយើងផងដែរ បើទោះបីជាបងប្អូនមាន ឬគ្មានឯកសារក៏ដោយ។

សេចក្តីដូចបានអំពាវនាវខាងលើ សូមបងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមេត្តារក្សាភាពនឹងនរ និងជឿទុកចិត្តលើសមត្ថភាព និងលទ្ធភាពទប់ស្កាត់ និងព្យាបាលជំងឺកូវីដ-១៩ របស់អាជ្ញាធរថៃ។

ក្នុងឱកាសឆ្លងឆ្នាំថ្មីឆ្នាំសកល២០២១នេះ គណៈកម្មការសូមបួងសួង និងជូនពរបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់សូមមានសុខភាពល្អ និងចាកផុតពីជំងឺកូវីដ-១៩ទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០
**រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ**

**អ៊ិត សំហេង**